# សុន្ទរកថាស្វាគមន៍
# ប្រធាន មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់
# ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ម.ត.ឯ.ច.)
# ក្នុងពិធីសម្ពោធឱ្យដំណើរការមជ្ឈមណ្ឌល
# ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១៧

- *សូមក្រាបបង្គំទូលថ្វាយបង្គំព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ*
- *សូមគោរព* ***ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី*** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*
- *សូមគោរព* ***ឯកឧត្តម. ហ៊ីដិហ៊ីហ្សា ហូរីនូជី.*** *ឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំប្រទេសកម្ពុជា ជាទីគោរព*
- *ឯកឧត្តមអគ្គរដ្ឋទូត តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដេវីដ សេហ្វ័រ សម្រាប់ អ.វ.ត.ក.*
- *សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងបណ្តាអ្នកសារព័ត៌មានទាំងឡាយជាទីគោរពរាប់អាន*

ក្នុងឱកាសដ៏មហាឡារឹកនាថ្ងៃនេះ តាងនាមមន្ត្រីរាជការនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ នាងខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងស្វាគមន៍ដ៏ស្មោះស្ម័គ្របំផុត ចំពោះឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការរៀបចំដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ អញ្ជើញជាអធិបតីមកផ្តល់ជាកិត្តិយសក្នុងពិធីសម្ពោធជាផ្លូវការរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាមួយគ្នានេះផងដែរ សូមគោរពនិងថ្លែងអំណរគុណ និងស្វាគមន៍ ឯកឧត្តម អគ្គរដ្ឋទូតជប៉ុនប្រចាំនៅកម្ពុជា និងឯកឧត្តមលោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ព្រមទាំងមន្ត្រីរាជការ និងអ្នកសារព័ត៌មានទាំងអស់ ដែលបានចូលរួមក្នុងថ្ងៃនេះ។

គណៈអធិបតីជាទីគោរព

អង្គពិធីទាំងមូលជាទីរាប់អាន

ក្នុងឱកាសនេះដែរ នាងខ្ញុំសូមជម្រាបជូន អង្គពិធីទាំងមូលដោយសង្ខេបថា មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ:១៥៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ជាស្ថាប័នរដ្ឋស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ការកសាងមជ្ឈមណ្ឌលនេះឡើង ដោយបានទទួលជំនួយឥតសំណងក្រៅគម្រោងរបស់ជប៉ុន និងរដ្ឋាភិបាលជប៉ុន ចំនួន២លើក។

- លើកទី១ គឺការកសាងអគារ និងបំពាក់គ្រឿងសង្ហារឹមៈ

ក្រោមជំនួយឥតសំណងក្រៅគម្រោងរបស់ជប៉ុនក្នុងគម្រោងហិរញ្ញបទានលើកទីមួយ សម្រាប់ការសាងសង់អគារទាំងមូលដែលរួមមានៈ ផ្នែកខាងលិចជាមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា និងផ្នែកខាងកើតជាគណៈមេធាវីកម្ពុជា រួមមានកំពស់ ៤ជាន់។ សម្រាប់អគារមជ្ឈមណ្ឌល មានបន្ទប់សរុបចំនួន២៦ និងបានបំពាក់សម្ភារៈគ្រឿងសង្ហារឹម តាមជាន់នីមួយៗរួចរាល់តាំងពីឆ្នាំ២០១២ ។

- លើកទី២ ជាការដាក់តំលើងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិក និងឧបករណ៍សម្ភារៈបន្ថែមៈ

ក្នុងគម្រោងជំនួយពីរដ្ឋាភិបាលជប៉ុនក្នុងដំណាក់ការលើកទី២ សម្រាប់ការរៀបចំបំពាក់ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិក នៅតាមបន្ទប់រួមមានដូចជាៈ ម៉ាស៊ីនត្រជាក់ទំហំធំ ទូតម្កល់ឯកសារ ប្រព័ន្ធទ្វារអេឡិចត្រូនិក កាមេរ៉ាសុវត្ថិភាព ប្រព័ន្ធបញ្ចេញឧស្ម័នពេលមានបញ្ហាអគ្គីភ័យ បន្ទះលោហបិទបង្អួច ប្រព័ន្ធចាប់ផ្សែង ប្រព័ន្ធសម្លេងពេលមានអាសន្ន បន្ទប់ប៊ូតសម្រាប់បកប្រែភាសា មីក្រូហ្វូន កាសស្តាប់សម្រាប់ការបកប្រែ ប្រព័ន្ធថតសម្លេង កុំព្យូទ័រ ធិបប្លែត Copy USER ធំ១ ពេលដាច់ភ្លើងអាចផ្គត់ផ្គង់បាន១៨ម៉ោង ប្រព័ន្ធម៉ាស៊ីនមេ ម៉ាស៊ីនភ្លើងដែលមានភ្ជាប់ប្រព័ន្ធ ATS ស្វ័យប្រវត្តិពេលភ្លើងដាច់។លនិងល។

គណៈអធិបតីជាទីគោរពដ៏ខ្ពង់ខ្ពស់

អង្គពិធីទាំងមូលជាទីមេត្រី

មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ទើបនឹងកសាង និងបង្កើតថ្មី រីឯមន្ត្រីក៏ទើបរើសបញ្ចូល នៅខ្វះបទពិសោធន៍ ប៉ុន្តែដោយមានការដឹកនាំចង្អុលបង្ហាញពីសំណាក់ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី និងមានការសហការយ៉ាងជិតស្និតជាមួយ អ.វ.ត.ក ដែលមានបទពិសោធន៍និងសមត្ថភាពពេញលេញ

បានជួយណែនាំចង្អុលបង្ហាញផ្លូវ និងជួយបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ប្រកបដោយផ្លែផ្កាយ៉ាងត្រចះត្រចង់ ។ សក្ដានុពលជ្រោមជ្រែងទាំងអស់នេះដែលបានផ្ដល់លទ្ធភាពឱ្យ ម.ត.ឯ.ច. ដំណើរការទៅបានរលូន និងដោយមានការគាំទ្រពីសំណាក់មជ្ឈដ្ឋាននានាជាច្រើនផងដែរ។

<u>អំពីស្ថានភាពមន្ត្រីៈ</u>

សព្វថ្ងៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ មានមន្ត្រីបម្រើការងារចំនួន១៣រូប ក្នុងនេះស្រី៧រូប ដែលមានសមាសភាពៈ មន្ត្រីក្របខ័ណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន៦រូប, មន្ត្រីជាប់កិច្ចសន្យា៦រូប និងរួមបន្ថែមជំនួយការប្រឹក្សាយោបល់១រូបផងដែរ។

<u>អំពីការបណ្ដុះបណ្ដាលមន្ត្រី</u>

ក្នុងឆ្នាំ២០១៦ អ.វ.ត.ក.បានទទួលយកមន្ត្រីរបស់ LDC ចំនួន៦រូប ឱ្យធ្វើកម្មសិក្សា ក្នុងរយៈពេល៧ខែ លើ៣មុខជំនាញៈ១ .ផ្នែកគ្រប់គ្រង និងថែរក្សាសំណុំរឿង,២. ផ្នែកព័ត៌មានវិទ្យា និងផ្នែកបណ្ណាល័យ។ ក្នុងឆ្នាំ២០១៧ នេះ អ.ក.ត.វ.បាននិងកំពុងទទួលយកមន្ត្រីរបស់ LDC ចំនួន៤រូប ឱ្យធ្វើកម្មសិក្សាបន្ថែមទៀតលើផ្នែកកិច្ចការរដ្ឋបាល សរសេរអត្ថបទសារព័ត៌មាន ការរចនាអត្ថបទ និងកាត់តរូបភាព ការរៀបចំកម្មវិធី និងទំនាក់ទំនងកិច្ចការសាធារណៈ ដើម្បីឱ្យមន្ត្រីកាន់តែមានភាពរឹងមាំអាចជួយការងារពោរពេញដោយសមត្ថភាពខ្ពស់។

<u>អំពីដើមបណ្ដឹងរដ្ឋប្បវេណីៈ</u> សម្រាប់សេចក្ដីពិតយុត្តិធម៌និងការចងចាំ យើងបានបង្កើត បន្ទប់ដើមបណ្ដឹងរដ្ឋប្បវេណី និងស្វាគមន៍ពួកគេមកគ្រប់ពេល ដើម្បីជួបជាមួយមេធាវីនិងសាច់ញាតិឬមិត្តភក្ដិរបស់ពួកគេហើយក្នុងនោះ ដើម្បីពិគ្រោះឯកសារខ្សែភាពយន្តនិងខ្សែភាពយន្តដែលរួមមានកំណត់ត្រាអំពីសក្ខីកម្មរបស់ពួកគេនៅក្នុងតុលាការ និងឯកសារផ្សេងទៀតដែលពួកគេចង់បានដើម្បីចែករំលែក។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានលើកទឹកចិត្តឱ្យដាក់សំភារៈឯកជនបន្ថែមទៀតនៅក្នុងកន្លែងផ្ទុកអចិន្ត្រៃយ៍ដែលមានការគាំទ្រពីសំណាក់បណ្ដារដ្ឋប្រជាមានិតប្រជាធិបតេយ្យ។ យើងកំពុងបង្ហាញឈ្មោះនិងរូបថតរបស់ពួកគាត់នៅ LDC ដែលចាប់ផ្ដើមពីអ្នកដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង 001 ។ ជាចុងក្រោយយើងបានគោរពដល់អ្នកដែលបានបាត់បង់ជីវិតនិងរងទុក្ខក្នុងរបបខ្មែរក្រហមដោយដាក់ឈ្មោះសាលប្រជុំរបស់យើងថា "សាលឈូកស នៃការចងចាំ" ។

<u>អំពីឯកសារតម្កល់ និងស្រាវជ្រាវ</u>

សព្វថ្ងៃ LDC មានប្រភេទឯកសារៈ

- ជាសំណុំឯកសារត្រូវផ្សព្វផ្សាយជាសាធារណៈនៃករណីកាំង ហ្គេចអ៊ាវ ហៅឌុច ០០១ Hard copy និង Soft Copy មានឯកសារសរុបចំនួន ៧០២៦ ស្មើនឹង៧០៧២៥ទំព័រ ដែលមាន៣ភាសា ភាសាខ្មែរ អង់គ្លេស និងភាសាបារាំង។ ក្រៅពីនោះ មជ្ឈមណ្ឌល មានឯកសារប្រភេទជា សៀវភៅ ទស្សនាវដ្តី អត្ថបទសារព័ត៌មាន និងជាវីដេអូ ដែលនិយាយពាក់ព័ន្ធនិងសាលាក្តី និងសម័យកម្ពុជាប្រជាធិបតេយ្យ។
- មជ្ឈមណ្ឌលបានធ្វើការដាក់បម្រើដល់សាធារណៈជនមកសិក្សាស្រាវជ្រាវនូវសំណុំឯកសារ សាធារណៈនៃករណី០០១ជា Soft copies តាមរយៈឧបករណ៍អេឡិចត្រូនិក មាន Computers និង Tablets ដោយប្រើប្រាស់ប្រព័ន្ធកម្មវិធី VT ។ កម្មវិធី VT នេះជា កម្មវិធីតែមួយនៅកម្ពុជា និងក្នុងចំណោមកម្មវិធីទំនើបបំផុតក្នុងពិភពលោក ហើយ យើងនឹងមានមន្ត្រីជំនាញនឹងជម្រាបជូនភ្ញៀវកិត្តិយសទាំងអស់នៅពេលបន្តិចទៀតនេះ។
- ក្រៅពីនេះភ្ញៀវអាចរកឯកសារតាមរយៈបញ្ជីសំណុំរឿង និងបញ្ជីសៀវភៅផ្សេងៗទៀត ដែលមានក្នុងបន្ទប់បណ្ណាល័យ។
- ចំណែកសំណុំឯកសារសាធារណៈនៃករណី០០១ ជា hard copies មិនត្រូវបានដាក់ ស្រាវជ្រាវទេ ដោយត្រូវរក្សាទុកក្នុងបន្ទប់តាមលក្ខណៈស្តង់ដាអន្តរជាតិ ដែលមាន ម៉ាស៊ីនត្រជាក់២៤ម៉ោង ក្នុងកម្រិតសីតុណ្ហភាព១៨ដឺក្រេ ពុំមានពន្លឺចូល មានឧបករណ៍ ការពារអគ្គីភ័យ ទ្វារសុវត្ថិភាព កាមេរ៉ាសុវត្ថភាព។លនិងល។

ឯកសារទាំងនេះ LDC ទទួលបានពីអង្គភាពគ្រប់គ្រងបណ្ណសាររបស់អ.វ.ត.ក. អង្គភាពគាំពារ ជនរងគ្រោះ(VSS), អង្គភាពបោះពុម្ពផ្សាយ(PAS), ដើមបណ្តឹងរដ្ឋប្បវេណី,បណ្ណសារដ្ឋានជាតិ, ពីមជ្ឈមណ្ឌលហាន់ដា ។

ទន្ទឹមនឹងនេះដែរ LDC នៅមានសក្តានុពលជាច្រើន បន្ទាប់ពីមានកិច្ចព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាល កម្ពុជា និងអង្គការសហប្រជាជាតិ រួមទាំងឯកសារគតិយុត្តិមួយចំនួនទៀត ដើម្បីទទួលបាននូវ សំណុំឯកសារសារធារណៈ និងកេរដំណែលរបស់អ.វ.ត.ក. សម្រាប់ធ្វើការគ្រប់គ្រង ថែរក្សា និងផ្សព្វផ្សាយជាសាធារណៈ។

គណៈអធិបតីជាទីគោរពដ៏ខ្ពង់ខ្ពស់
អង្គពិធីទាំងមូលជាទីមេត្រី

ជំនួសមុខឱ្យមន្ត្រីរាជការនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ទាំងអស់ យើងខ្ញុំសូមត្រៀមខ្លួនជានិច្ចទទួលនូវរាល់អនុសាសន៍ និងគោលនយោបាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការណែនាំអនុវត្តន៍ផ្ទាល់ពី **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបង្កើនសមត្ថភាព ប្រសិទ្ធភាព ក្នុងការបំពេញតួនាទី និងភារកិច្ចដែលកំណត់ក្នុងអនុក្រឹត្យលេខ:១៥៩អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ឱ្យកាន់តែប្រសើរឡើងថែមទៀត។

នាងខ្ញុំព្រះករុណាខ្ញុំ សូមអភ័យទោសពីសំណាក់ ឯកឧត្តម **ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ឯកឧត្តមអគ្គរដ្ឋទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ដោយនាងខ្ញុំសូមលើកយកសំណូមពរជាតម្រូវការចាំបាច់មានដូចជា:

- តួនាទីនិងភារកិច្ច តម្រូវឱ្យមានមន្ត្រីក្របខ័ណ្ឌបន្ថែមទៀតសម្រាប់បម្រើការងារនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ដើម្បីយើងអាចបំពេញតួនាទីជាមជ្ឈមណ្ឌលគំរូតាមបទដ្ឋានអន្តរជាតិ។
- សូមជួយជម្រុញ និងសម្របសម្រួលបន្ថែមទៀតរាល់កិច្ចការរបស់មជ្ឈមណ្ឌលឱ្យមានដំណើរការបានទៅដោយរលូន និងឆាប់រហ័សទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។
- ដោយមានតម្រូវការចាំបាច់ក្នុងការទំនាក់ទំនងដោយផ្ទាល់ រវាងមជ្ឈមណ្ឌលនិងស្ថាប័នជាតិ និងអន្តរជាតិ ជាពិសេសជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការចល័តឯកសារមកមជ្ឈមណ្ឌល ដើម្បីធានានូវសុវត្ថិភាព និងគុណភាពចំពោះឯកសារទាំងនេះ។ មជ្ឈមណ្ឌលសំណូមពរឱ្យមានមធ្យោបាយដឹកជញ្ជូនសម្រាប់អង្គភាពផ្ទាល់។
- សំណូមពរអង្គការដៃគូ នានាជួយផ្តល់ជាសៀវភៅ ឬឯកសារទាំងឡាយដែលបានផលិតបោះពុម្ពផ្សាយ ពាក់ព័ន្ធនឹងសាលាក្តីខ្មែរក្រហម ។

ពីថ្ងៃនេះទៅ យើងត្រៀមខ្លួនចាំទទួល និងផ្តល់សេវាកម្មដល់អ្នកស្រាវជ្រាវ ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី និងសហការជាមួយអ.វ.ត.ក. ព្រមទាំងអង្គការ និងស្ថាប័នដៃគូពាក់ព័ន្ធនានា សម្រាប់ជាប្រភពរួមរក្សាទុកដល់អ្នកជំនាន់ក្រោយៗ បានសិក្សាស្រាវជ្រាវ និងយល់ដឹងពីការងារប្រវត្តិសាស្ត្ររបស់អ.វ.ត.ក. ក្នុងការខិតខំប្រឹងប្រែងស្វែងរកយុត្តិធម៌ ដល់ប្រជាជនរងគ្រោះក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់១៩៧៩។

អាស្រ័យហេតុនេះសូម **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** មេត្តាជួយសម្រួលដោយក្តីអនុគ្រោះបំផុត។

នាងខ្ញុំសូមបួងសួងដល់ទេវតាឱ្យប្រសិទ្ធិពរជ័យ សិរីសួស្តីជ័យមង្គលដ៏ប្រសើរជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងលោកជំទាវព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ។

សូមគោរពជូនពរ ឯកឧត្តមឯកអគ្គរដ្ឋទូតជប៉ុន ឯកឧត្តម លោកជំទាវ លោក លោកស្រីជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អង្គពិធីទាំងមូល សូមឱ្យមានសុខភាពល្អ និងទទួលបានជ័យជំនះគ្រប់ភារកិច្ច។

សូមអរព្រះគុណ និងសូមអរគុណ